JICA Cambodia Office - JICA カンボジア事務所

November 7, 2023 ·

[សិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំថ្នាក់ជាតិ លើកទី២ ស្តីពីការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក/2nd Dissemination Workshop of the National Guideline on In-Service Training for Nurses (INSET)]

-------------------------------

នៅថ្ងៃទី១ ខែវិច្ឆិកា ឆ្នាំ២០២៣ ក្រសួងសុខាភិបាល (MoH) និងទីភ្នាក់ងារសហប្រតិបត្តិការអន្តរជាតិជប៉ុន (JICA) បានរៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំថ្នាក់ជាតិ លើកទី២ ស្តីពីការបណ្តុះបណ្តាលក្នុងពេលបម្រើការងារសម្រាប់គិលានុបដ្ឋាក (INSET) ក្រោមគម្រោងពង្រឹងប្រព័ន្ធបណ្តុះបណ្តាលក្នុងពេលបម្រើការងារនៅកម្ពុជា (Strings) នៅសណ្ឋាគារ អិល ប៊ី អិន អាស៊ាន ក្នុងខេត្តកំពង់ចាម។

អញ្ជើញចូលរួមជាគណៈអធិបតីក្នុងសិក្ខាសាលានេះមាន ឯកឧត្តមសាស្ត្រាចារ្យ ម៉ម ប៊ុនសុជាតិ អនុរដ្ឋលេខាធិការក្រសួងសុខាភិបាល តំណាងឲ្យឯកឧត្តមសាស្ត្រាចារ្យ ធា គ្រុយ រដ្ឋលេខាធិការក្រសួងសុខាភិបាល និងជានាយកគម្រោង លោកស្រីសាស្ត្រាចារ្យជំនួយ ទូច សុខនាង ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ធនធានមនុស្ស និងជាអ្នកគ្រប់គ្រងគម្រោង ព្រមទាំងមានការអញ្ជើញចូលរួមផងដែរពីលោកប្រធានគណៈគិលានុដ្ឋាកកម្ពុជា ឯកឧត្តម លោក-លោកស្រី ជាប្រធាន-អនុប្រធាន មន្ទីរសុខាភិបាលនៃរដ្ឋបាលខេត្ត លោក-លោកស្រី ជាប្រធាន-អនុប្រធាន មន្ទីរពេទ្យខេត្ត ទាំង ១៦ រួមមាន ខេត្តកំពង់ចាម បាត់ដំបង ស្ទឹងត្រែង សៀមរាប កំពង់ឆ្នាំង ពោធិ៍សាត់ ត្បូងឃ្មុំ កំពង់ធំ ព្រះវិហារ ស្វាយរៀង ព្រៃវែង ក្រចេះ រតនៈគីរី មណ្ឌលគីរី បន្ទាយមានជ័យ និងខេត្តឧត្តរមានជ័យ និង លោក-លោកស្រី ជានាយករងសាលាមធ្យមសិក្សាសុខាភិបាលភូមិភាគកំពង់ចាម ស្ទឹងត្រែង និងបាត់ដំបង។

បន្ទាប់ពីការធ្វើបទបង្ហាញជាបន្តបន្ទាប់អំពី ទិដ្ឋភាពទូទៅនៃគម្រោង ដំណើរការនៃការបង្កើតគោលការណ៍ណែនាំថ្នាក់ជាតិ និងទិដ្ឋភាពទូទៅនៃគោលការណ៍ណែនាំថ្នាក់ជាតិ ក៏មានពិធីប្រគល់សៀវភៅគោលការណ៍ណែនាំថ្នាក់ជាតិ ជានិមិត្តរូប ជូនដល់ឯកឧត្តម លោក-លោកស្រីចំនួន ៥រូប តំណាងឲ្យសិក្ខាកាមដែលបានចូលរួម។ អំឡុងពេលពិភាក្សា គិលានុបដ្ឋាកចុះបញ្ជីការ និងការអនុលោមច្បាប់ដែលជាមូលដ្ឋានរបស់ ការអភិវឌ្ឍវិជ្ជាជីវៈបន្ត (CPD) ត្រូវបានពិភាក្សាផងដែរ៕

អត្ថបទ៖ ផ្នែកអភិវឌ្ឍន៍សង្គម និងអភិបាលកិច្ច, Strings Project

រូបថត៖ ការិយាល័យចៃកាប្រចាំកម្ពុជា

On 1st November 2023, Ministry of Health (MoH) and Japan International Cooperation Agency (JICA) has jointly organized the 2nd dissemination workshop of the national guideline on in-service training for nurses (INSET), under the project for strengthening in-service training system in Cambodia (Strings), at LBN Asian Hotel in Kampong Cham.

H.E. Prof. Mam Bunsocheat, Under Secretary of State, MoH, presided over this occasion as a representative of H.E. Prof. Thir Kruy, Secretary of State, MoH, and the project director. Among the attendees were Asst. Prof. Touch Sokneang, Director of the Department of Human Resource Development, the project manager, the president of the Cambodian Council of Nurses (CCN), directors and deputy directors of provincial administrative health departments, provincial referral hospitals from 16 provinces: Kampong Cham, Battambang, Steung Treng, Siem Reap, Kampong Chhnang, Pursat, Tboung Khmum, Kampong Thom, Preah Vihear, Svay Rieng, Prey Veng, Kratie, Ratanakiri, Mondulkiri, Banteay Meanchey and Oddar Meanchey, and deputy directors from regional training centers of Kampong Cham, Steung Treng and Battambang.

There were several presentations, such as the Strings project overview, the process of developing the INSET guideline, and an overview of the INSET guideline. Also, 5 attendees were selected as the representative of everyone for the handover of the guideline book as a symbol. During the discussion, the registration of nurses and compliance with the law, which are the basis for Continuing Professional Development (CPD), were actively discussed.

Article credit: Social development and governance sector, Strings Project














